**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**

**លេខ:** ០០៤៤/១៧ ភ.ព.ន.ព.រ.ហ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃសុក្រ ទី 04 ខែ សីហា ឆ្នាំ ២០១៧

នៅថ្ងៃសុក្រទី០៤ ខែសីហា ឆ្នាំ ២០១៧ វេលាម៉ោង៨ ព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/005 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៣។**

**២- សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវការលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។**

**៣- បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ** «ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្របខណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខណ្ឌនេះ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន»។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

**១- សេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្មដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/005 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០៣។**

ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងអនុវត្តច្បាប់នេះ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ សំដៅលើក



ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខ: ០២៣ ២១២ ៩៤០, ទូរស័ព្ទ: ០១២ ៩៩៩ ៩៧៦, ០៩៧ ៧ ៩៧០ ៦០៤
អ៊ីមែល: pressocm@gmail.com

ទឹកចិត្តចំពោះការច្នៃប្រឌិតថ្មី និងចំពោះការស្រាវជ្រាវ និងការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា, ជំរុញ និងលើកទឹកចិត្តការធ្វើពាណិជ្ជកម្មក្នុង និងក្រៅប្រទេស និងការវិនិយោគ, លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិជ្ជាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងផ្ដល់ការការពារចំពោះសិទ្ធិនៃសិទ្ធិឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើ ក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់។

ក្នុងក្របខណ្ឌអន្តរជាតិ តាមការសម្រេចដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី កម្ពុជាបានចូលជាសមាជិកទី១៥១ នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ និងចូលជាសមាជិកទី៦៦ នៃសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៩៩ នៃកិច្ចព្រមព្រៀងទីក្រុងហេច ទាក់ទងនឹងការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧។

ការធ្វើវិសោធនកម្មច្បាប់នេះ នឹងនាំមកនូវការជំរុញកិច្ចការពារកម្មសិទ្ធិបញ្ញា ការច្នៃប្រឌិត និងការបង្កើតថ្មី ការស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា លំហូរបច្ចេកវិជ្ជាថ្មីៗពីបរទេស កំណើនការវិនិយោគ រួមទាំងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិ។

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

អនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ការងាររបបសន្តិសុខសង្គមផ្នែកហានិភ័យ (គ្រោះថ្នាក់ការងារ) ត្រូវបានអនុវត្តតាំងពីខែវិច្ឆិកា ឆ្នាំ២០០៨ និងផ្នែកថែទាំសុខភាពនៅខែមករា ឆ្នាំ២០១៦។ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៧ មានសហគ្រាសចំនួន៩,១៦៥ កម្មករនិយោជិតសរុប១,១៦៦,៧៣៦នាក់ បាននិងកំពុងអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ក្នុងនោះបានដោះស្រាយករណីគ្រោះថ្នាក់ការងាររួមមាន៖ គ្រោះថ្នាក់នៅកន្លែងធ្វើការ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ បានចំនួន១៦១,៥៣៩នាក់។ ដោយឡែកផ្នែកថែទាំសុខភាពគិតត្រឹម ឆមាសទី១ ឆ្នាំ២០១៧ បានកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញបានចំនួន៧៥៤រោងចក្រ និងសហគ្រាសដែលមានកម្មករនិយោជិតចំនួន៨២៧,០៦០នាក់ ជាសមាជិក។

ដើម្បីលើកកម្ពស់សុខមាលភាពសង្គមឱ្យកាន់តែប្រសើរ និងធានាសង្គតិភាពក្នុងការគាំពារផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព រវាងកម្មករនិយោជិតក្នុងវិស័យឯកជន និងមន្ត្រីរាជការក្នុងវិស័យសាធារណៈ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានឯកភាពប្រគល់ភារកិច្ចឱ្យបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ជាអ្នករៀបចំ និងគ្រប់គ្រងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនតាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

អនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនត្រូវបានរៀបចំឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មាន៧ជំពូក និង២៨មាត្រា ដោយមានគោលបំណងកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារចំពោះមន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពចំពោះមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន លើកលែងតែអតីតយោធិនដែលមានឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី ដែលបានទទួលរបបព្យាបាលពិសេសតាមស្មារតី នៃអនុក្រឹត្យលេខ១៩៩ អនក្រ.បកចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៣ ស្តីពីបែបបទនៃការទទួលសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពទាំងប្រាំនៃយោធិនអាជីព និងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍។

៣- **បញ្ហាផ្សេងៗ** ៖ អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូន «ពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងក្រខណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ និងកិច្ចព្រមព្រៀងមួយចំនួនទៀតក្រោមកិច្ចព្រមព្រៀងក្របខណ្ឌនេះរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងសាធារណរដ្ឋប្រជាមានិតចិន» ទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបាន៖

- សម្រេចយកថ្ងៃអាទិត្យរៀងរាល់សប្តាហ៍ ចាប់ពីថ្ងៃទី២០ ខែ សីហា ឆ្នាំ ២០១៧ តទៅ ដើម្បីទទួលជួបសំណេះសំណាល និងចុះសួរសុខទុក្ខ កម្មករ និយោជិត នៅតាមបណ្តារោងចក្រ ដើម្បីស្វែងយល់ពីសុខទុក្ខ និងតម្រូវការនានា។

- ណែនាំដល់ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យការអនុវត្តច្បាប់ពន្ធលើប្រាក់បៀវត្សរ៍ ចំពោះបុគ្គលិក អង្គការក្រៅរដ្ឋាភិបាលនានា ដែលបាននិងកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យមានតម្លាភាព និងសមភាព។

- ណែនាំឱ្យក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រៀមរៀបចំសម្រាប់កិច្ចប្រជុំគណៈរដ្ឋមន្ត្រីចំរុះកម្ពុជា-ថៃ លើកទី០៣ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី ០៧ ទី០៨ ខែកញ្ញា ឆ្នាំ ២០១៧ ខាងមុខនេះ ក្នុងនាមជាម្ចាស់ផ្ទះឱ្យបានល្អ ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង ១០ និង ០០នាទី។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី០៤ ខែសីហា ឆ្នាំ២០១៧